# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា៦ និងមាត្រា១៤ នៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

**មាត្រាមួយ .-**

ត្រូវបានកែសម្រួលមាត្រា៦ និងមាត្រា១៤ នៃអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា ដូចតទៅ :

**មាត្រា៦ ថ្មី .-**

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ដែលជាគ្រឹះស្ថានសាធារណរដ្ឋបាល មានរចនាសម្ព័ន្ធ ដូចតទៅ :

១-នាយកដ្ឋានរដ្ឋបាល បុគ្គលិក ហិរញ្ញកិច្ច និងទំនាក់ទំនងសាធារណៈ
២-នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី ១
៣-នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី ២
៤-នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ
៥-នាយកដ្ឋាននគរូបនីយកម្ម និងអភិវឌ្ឍន៍តំបន់សៀមរាប-អង្គរ
៦-នាយកដ្ឋានប្រជាសាស្ត្រ និងការងារអភិវឌ្ឍន៍
៧-នាយកដ្ឋានទឹក និងព្រៃឈើ
៨-នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ

**មាត្រា១៤ ថ្មី .-**

នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ មានភារកិច្ច ដូចតទៅ :

-ការពារ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា

-សហការជាមួយនាយកដ្ឋាននានារបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ដើម្បីក្តាប់បានផែនទីប្លង់មេនៃតំបន់ទាំង៥ ដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា ហើយលើកផែនការ និងវិធានការ ក្នុងការចាត់ចែងកងកម្លាំងឱ្យការពារនៅតាមគោលដៅនានាដែលបានកំណត់

-ក្តាប់សភាពការណ៍ និងស្រាវជ្រាវរកឱ្យឃើញនូវបទល្មើសដែលបម្រុងកើត ឬកើតឡើងភ្លាមៗលើការកាប់បំផ្លាញព្រៃឈើ ការរុករានដីព្រៃព័ទ្ធរបង ការសាងសង់លំនៅដ្ឋាន និងសំណង់ អគារនានា ដែលគ្មានលិខិតអនុញ្ញាតស្របច្បាប់ ក្នុងតំបន់ត្រូវការពារដោយអាជ្ញាធរអប្សរាបានកំណត់ឱ្យ ហើយធ្វើការអប់រំ បង្ការទប់ស្កាត់ និងលើកវិធានការដោះស្រាយតាមករណីនីមួយៗ

-សហការជាប្រចាំជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នគរបាល កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការទប់ស្កាត់ និងមានវិធានការចំពោះការកាប់បំផ្លាញព្រៃឈើ ការរំលោភបំពានព័ទ្ធរបងយកដី ការសាងសង់លំនៅដ្ឋាន និងសំណង់ អគារដែលគ្មានច្បាប់អនុញ្ញាតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ដែលត្រូវការពារដោយអាជ្ញាធរអប្សរា

-សហការជាមួយនគរបាលការពារបេតិកភ័ណ្ឌ ដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើគាស់ រុករក និងលួចវត្ថុបុរាណ ក្នុងតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-សហការជាមួយអង្គភាពនគរបាលទេសចរណ៍ ក្នុងករណីមានការពាក់ព័ន្ធដល់កិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ សៀមរាប និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់សាមីនាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនអគ្គនាយកនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់អគ្គនាយក អគ្គនាយករងទទួលបន្ទុក និងប្រធានអាជ្ញាធរអប្សរា ។

**មាត្រាពីរ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អគ្គនាយកនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា អភិបាលខេត្ត ក្រុងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

សុខ អាន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-ឯកសារ កាលប្បវត្តិ